STREAM

គោលនយោបាយ

សង្ខេប

www.streaminitiative.org

លេខ ២

ខែ មីនា ឆ្នាំ ២០០៥

សង្ខេប

**តើអត្ថបទនេះពិព័ណ៌នាអំពីអ្វី?** ធ្វើការវិភាគ និង ជួយដល់ប្រជាជនដែលស្ថានភាពជីវភាពរបស់ពួកគាត់ពឹងផ្អែកលើវិស័យជលផល និង វារីវប្បកម្ម ។

### សូមអានអត្ថបទនេះ ប្រសិនបើ...

..លោកអ្នកចង់យល់ដឹងឱ្យបានកាន់តែច្បាស់ថែមទៀតពីកម្មវត្ថុ ភាពទទួលរងគ្រោះថ្នាក់ ធនធាន និង បរិប័ទនៃការរស់នៅរបស់ប្រជាជន ។

### ការផ្លាស់ប្តូរនេះពាក់ព័ន្ធនឹង :

- ទទួលស្គាល់នូវតួនាទីដ៏មានមានសារសំខាន់ចំពោះការគ្រប់គ្រងវិស័យជលផលថ្នាក់ជាតិក្នុងការកាត់បន្ថយភាពក្រីក្រ ។
- កសាងសមត្ថភាពយល់ដឹងនូវការវិភាគពីជីវភាពរស់នៅ និង ទិសដៅនៃការរៀបចំជីវភាពរស់នៅដើម្បីធ្វើការអភិវឌ្ឍន៍បន្ថែមទៀត ។
- ពិចារណាលើជម្រើសដែលបង្កើតឡើងដោយប្រជាជន ។ ពីធនធានដែលប្រជាជនអាចទទួលបាន និង ពេលវេលាដែលពួកគាត់ប្រើប្រាស់សម្រាប់ជួយធ្វើឱ្យប្រសើរឡើងដល់*ជីវភាពរស់នៅ*។
- ផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍថ្នាក់ជាតិ (ដូចជា NSSDs, CDFs និង PRSPs) ស្តីពីបរិប័ទនៃជីវភាពរស់នៅរបស់ប្រជាជនដែលជាអ្នកបង្កើត និង អនុវត្តគោលនយោបាយនោះ ។
- ពង្រឹងនូវទំនាក់ទំនងរវាងមូលហេតុនៃភាពក្រីក្រ ជាមួយនឹងកសិករ និង ប្រជានេសាទ ពីរាល់ការឆ្លើយតបដែលទទួលបានពីការអនុវត្តគោលនយោបាយជាបន្តបន្ទាប់ ។

ការវិភាគអំពីស្ថានភាពជីវភាពរស់នៅដោយប្រើប្រាស់វិធីសាស្ត្រនៃការចូលរួម គឺតែងអនុវត្តដោយក្រុម-ពួកនៅក្នុងសហគមន៍ ។

គោលដៅ និង ការវិភាគអំពីស្ថានភាពជីវភាពរស់នៅគឺជាវិធីមួយដែលអាចសម្របសម្រួលទៅតាមរបៀបបំពេញការងារ ដោយផ្តោតជាសំខាន់ទៅលើមនុស្ស គឺមិនមែនទៅលើការគ្រប់គ្រងធនធានវារីជាតឡើយ និងទៅ តាមរបៀបវារៈដែលបានរៀបចំឡើង ។

យើងអាចចាត់ទុកការរៀនសូត្រអំពីជីវភាពរស់នៅរបស់ប្រជាជនជាជម្រើសដ៏មានប្រយោជន៍មួយសម្រាប់កែតម្រូវ ត្រួតពិនិត្យ និង វាយតម្លៃពីការខិតខំរបស់យើងសំដៅធ្វើឱ្យសម្រេចបានតាមគោលបំណងរបស់ប្រជាជនក្រីក្រ ។

សេចក្តីសង្ខេបស្តីពី....

# ទិសដៅនៃការបង្កើនជីវភាពរស់នៅដោយផ្តោតលើវិស័យជលផល និង វិស័យវារីវប្បកម្ម

...តែ ២ ទំព័រ ឬតិចជាង

**ប្រសិនបើលោកអ្នកអាចធ្វើអ្វីមួយដើម្បីរួមចំណែកដល់គោលនយោបាយសង្ខេបនេះ “ this Policy Brief” សូមចូលរួមធ្វើ...**

**កសាងជំនាញ និង រៀបចំវិធីដើម្បីបំពេញការងារនៅក្នុងអង្គភាពឱ្យទទួលបាននូវវិជ្ជាជីវៈជលផល សមត្ថភាពនៃការយល់ដឹង និង ជួយដល់ការគ្រប់គ្រងធនធានវារីជាត សម្រាប់ស្តារជីវភាពរស់នៅរបស់ប្រជាជន ជាពិសេសអ្នកដែលទទួលបានផលពីធនធានបានតិចតួច ។**

## សេចក្តីសង្ខេប....

នាំមកនូវសេវាកម្ម និង គោលនយោបាយដ៏ល្អសម្រាប់ជួយគាំទ្រដល់គោលដៅរបស់ប្រជាជនឱ្យមានប្រសិទ្ធភាពដោយពឹងផ្អែកលើប្រការជាច្រើន ដោយពេលខ្លះ អាចជាជម្លោះ ឬរបៀបវារៈផ្សេងៗ។ មានសមាសភាព ៣ ជាសំខាន់គឺ : សមត្ថភាពដើម្បីធ្វើការវិភាគនិងស្វែងយល់ពីជីវភាពរស់នៅរបស់ប្រជាជន ពិចារណានូវទស្សនៈវិស័យរបស់ជាតិ និង ធ្វើការផ្តួចផ្តើមគំនិតតាមរយៈសហគមន៍អន្តរជាតិដើម្បីអំពាវនាវស្វែងរកនូវការគាំទ្រយុទ្ធសាស្ត្រអភិវឌ្ឍថ្នាក់ជាតិ ឱ្យបានកាន់តែច្រើនឡើង ។

- នៅតំបន់អាស៊ី-ប៉ាស៊ីហ្វិច ការគាំទ្ររបស់រដ្ឋាភិបាលថ្នាក់ជាតិដល់ការគ្រប់គ្រងធនធានវារីជាតគឺមាននិន្នាការផ្តោតជាសំខាន់ទៅលើការស្រាវជ្រាវ និង ការអភិវឌ្ឍបច្ចេកវិទ្យា។ ជាមួយគ្នានេះដែរ យើងទទួលបាននូវ **តួនាទីដ៏មានសារសំខាន់យ៉ាងធំធេងសម្រាប់គ្រប់គ្រងវិស័យជលផលថ្នាក់ជាតិដើម្បីលុបបំបាត់ភាពក្រីក្រ** ដែលយើងត្រូវតែយល់ឱ្យបានច្បាស់នូវតួនាទីរបស់វិស័យជលផលចំពោះជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ ។
- ដើម្បីធ្វើឱ្យសម្រេចបាននូវការងារទាំងនេះ ការពង្រឹងសមត្ថភាពត្រូវតែធ្វើការយកចិត្តទុកដាក់ដើម្បីធ្វើយ៉ាងណាឱ្យអាចយល់កាន់តែច្បាស់ពីការវិភាគនូវស្ថានភាពរស់នៅ និង គោលដៅរបស់វា ដើម្បីធ្វើការអភិវឌ្ឍឱ្យបានកាន់តែប្រសើរឡើង ។
- *ការវិភាគពីស្ថានភាពរស់នៅ* គឺជា**ប្រព័ន្ធគោលដៅដែលអាចបត់បែនបាន ដើម្បីឱ្យមានការយល់បាន** ពីស្ថានភាព សិទ្ធប្រើប្រាស់ធនធាន ភាពងាយទទួលរងគ្រោះ បំណង និង ជម្រើស ដោយប្រើនូវគោលដៅមួយធ្វើឱ្យមានការចូលរួមរៀនសូត្រពីក្រុម ឬ បុគ្គលនៅក្នុងសហគមន៍។ វាមិនមែនជាការស្មុកស្មាញឡើយ ប៉ុន្តែតែងពាក់ព័ន្ធជាមួយនឹងអ្នកថ្មីដែលមានតួនាទីភារកិច្ចជាមួយនឹងការងារនោះ ។
- *ការជ្រើសរើសយកទិសដៅស្តារជីវភាពរស់នៅ*ត្រូវពិចារណាទៅលើ **ជម្រើសដែលប្រជាជនប្រកាន់យក ធនធានដែលពួកគាត់អាចទទួលបាន និង ពេលវេលាដែលពួកគាត់អាចប្រើប្រាស់សម្រាប់ជួយដល់***ជីវភាពរស់នៅ*។ វាអាចមានភាពស្មុក-ស្មាញខ្លះៗ ជាពិសេសការផ្តោតជាសំខាន់ទៅលើមនុស្ស គឺមិនមែនទៅលើការគ្រប់គ្រងធនធានវារីជាតឡើយ និង ទៅតាមរបៀបវារៈដែលបានរៀបចំ ឡើង ។
- វាមានប្រយោជន៍ដើម្បី***ពង្រីកគោលដៅរបស់យើងទៅលើការគ្រប់គ្រងធនធានវារីជាត*** ជំនួសឱ្យការធ្វើវារីវប្បកម្ម ឬការ-ងារជលផល ឬការដាំដុះ ពីព្រោះ ការងារនេះអាចជួយយើងឱ្យជៀសផុតនូវរាល់ឧបសគ្គដល់របៀបវារៈនៃវិស័យបន្ទាប់បន្សំមួយទៀតរបស់យើង នៅពេលដែលយើងដឹងថា ជីវភាពរស់នៅរបស់ប្រជាជនជួបប្រទះនូវលំបាក ។ យើងដឹងយ៉ាងច្បាស់ថាភាពងាយទទួលរងគ្រោះដោយការជ្រើសរើសឱ្យសមហេតុសមផលនូវជម្រើសបញ្ចូលគ្នាជាច្រើនចំពោះជីវភាពរស់នៅដែលអាចរួមបញ្ចូលនូវសកម្មភាពអន្តរទំនាក់ទំនងដែលពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានវារិជាត ដូចជា ការដាំដុះ ការនេសាទ ការធ្វើវារីវប្បកម្ម ការងារពលកម្ម ការងារតាមរោងចក្រ និង ការផ្តល់សេវាកម្មនានា ។

→ មនុស្សជាច្រើនដែលពាក់ព័ន្ធក្នុងការងារគ្រប់គ្រងវិស័យជលផលគឺតែងបានបំពាក់បំប៉ននូវចំណេះដឹងបច្ចេកទេស ប៉ុន្តែ អាចនៅតែត្រូវការពង្រឹងសមត្ថភាពបន្ថែម ដើម្បីឱ្យមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ធ្វើការវិភាគពីជីវភាពរស់នៅ និង អនុវត្តវាឱ្យចំទិសដៅអភិវឌ្ឍជីវភាពរស់នៅបានសមស្រប ។

## សេចក្តីសង្ខេបស្តីពី...ទិសដៅនៃជីវភាពរស់នៅ

- ទិសដៅនៃជីវភាពរស់នៅ គឺធ្វើយ៉ាងណាឱ្យបានកាន់តែ**ប្រសើរឡើងនូវការយល់ដឹងស៊ីជម្រៅ** សំដៅធ្វើឱ្យមនុស្សមានការអភិវឌ្ឍន៍ និង ចែករំលែកនូវព័ត៌មានឱ្យគ្នាទៅវិញទៅមក រវាងមនុស្ស និង អន្តរអំពើជាមួយនឹងធនធានរបស់ពួកគាត់។
- ការចាប់យកគោលដៅនៃការអភិវឌ្ឍជីវភាពរស់នៅ ជួយយើងឱ្យទទួលស្គាល់ និង ចចារឡើងវិញពីទំនាក់ទំនងដែលមិនមានអំណាចស្មើគ្នា ដោយព្យាយាមមិនបញ្ចេញនូវទស្សនៈតែឯង (ភាពលុបលើ) ប៉ុន្តែ ជាលំដាប់លំដោយនៃទស្សនៈ និង ធ្វើឱ្យប្រាកដថា ការយល់ដឹង និង ចំណេះដឹងរបស់ពួកគាត់ស៊ីគ្នាទៅនឹងរបៀបវារៈ តារាងពេលវេលា គម្រោងថវិកា និងវិធីនៃការបំពេញការងារ។
- លទ្ធផលពីរដែលអាចសម្រេចទៅបាននៃការធ្វើឱ្យប្រសើរឡើងនូវទិសដៅនៃជីវភាពរស់នៅក្នុងវិស័យជលផលគឺគប្បី ៖ ពង្រឹងទំនាក់ទំនងរវាងឫសគល់នៃភាពក្រីក្ររបស់កសិករ និង អ្នកនេសាទ ទៅនឹងការផ្តល់នូវគោលនយោបាយជាបន្តបន្ទាប់ និង លើកឡើងនូវគោលសំខាន់ៗឱ្យកាន់តែច្បាស់លាស់ថែមទៀតពីតួនាទីដ៏សំខាន់ដែលធនធានវារីជាតដើរតួសម្រាប់ធ្វើឱ្យប្រសើរដល់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ។
- តាមរយៈការប្រើនូវទិសដៅអភិវឌ្ឍជីវភាពរស់នៅ យើងអាចធ្វើការបកស្រាយនូវមេរៀនស្តីពី ជីវភាពរស់នៅរបស់ប្រជាជន ដែលជាប្រធានបទមួយដ៏មានប្រយោជន៍សម្រាប់ធ្វើការផ្លាស់ប្តូរ និង វាយតម្លៃ នូវការខិតខំរបស់យើង ជាមួយនឹងគោលបំណងរបស់ប្រជាជនក្រីក្រ។
- ប្រសិនបើ គោលដៅនៃការអភិវឌ្ឍន៍ជីវភាពរស់នៅ អាចមានសារសំខាន់ដើម្បីធ្វើឱ្យប្រសើរឡើងដល់ការនាំមកនូវសេវាកម្មមូលដ្ឋាន និង ការអភិវឌ្ឍន៍គោលនយោបាយ ដែលពួកគេអាចរួមចំណែកផងដែរដល់ថ្នាក់ជាតិបានយ៉ាងទូលំទូលាយ ដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងនូវយុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍ក៏វិតថ្នាក់ជាតិ (ដូចជា NSSDs, CDFs និង PRSPs – ដូចមានក្នុងប្រអប់ខាងក្រោម)។

***ការតព្វកិច្ចរបស់អន្តរជាតិ និង គោលដៅនៃជីវភាពរស់នៅ :***

- របៀបវារៈទី ២១ ផែនការសកម្មភាពនៃកិច្ចប្រជុំកំពូល ឆ្នាំ ១៩៩២ (Rio Earth Summit, 1992) អំពាវនាវឱ្យបណ្តាប្រទេសទាំងអស់យកចិត្តទុកដាក់ចំពោះយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់អភិវឌ្ឍន៍ឱ្យមាននិរន្តរភាព (NSSD) ដើម្បីឱ្យមានចិរភាពផ្នែកសង្គម បរិស្ថាន និង សេដ្ឋកិច្ចយ៉ាងច្បាស់លាស់។
- ធនាគារពិភពលោកលើកទឹកចិត្តឱ្យមានក្របខ័ណ្ឌការងារអភិវឌ្ឍន៍ទូលំទូលាយ (CDFs)។
- ធនាគារពិភពលោក និង មូលនិធិរូបិយប័ណ្ណអន្តរជាតិប្រើប្រាស់ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រជាមធ្យោ - បាយសម្រាប់ធ្វើការបន្ធូរបន្ថយបំណុលដែលជាលទ្ធផលនៃការកាត់បន្ថយភាពក្រីក្រ (បច្ចុប្បន្ននេះ ចំណុចស្នូលសម្រាប់ធ្វើការពិភាក្សាគោលនយោបាយនៅតាមប្រទេសដើម្បីឱ្យទទួលបានកម្ចីសម្បទានពីធនាគារ និង មូលនិធិរូបិយប័ណ្ណអន្តរជាតិ)។
- NSSDs, CDFs និង PRSPs គឺជាជំពូកនីមួយៗនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់ជាតិ ដែលទាក់ទងនឹងគោលដៅនៃជីវភាពរស់នៅ។
- នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិច ការគ្រប់គ្រងធនធានវារីជាតសម្រាប់ជួយដល់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ គឺមានតួនាទីយ៉ាងសំខាន់នៅក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់ជាតិ។

**ភ្ជាប់គ្នាទៅនឹងប្រភពព័ត៌មាន និង ឯកសារដទៃទៀតដែលទាក់ទងទៅនឹងប្រធានបទខាងលើនេះ :**

- សេចក្តីណែនាំចំនួន ១៨ ទំព័រនេះ បង្ហាញពីការប្រៀបធៀបនូវទិសដៅនៃការអភិវឌ្ឍន៍របស់នាយកដ្ឋានចក្រភពអង់គ្លេសដើម្បីអភិវឌ្ឍន៍អន្តរជាតិ http://www.livelihoods.org/info/guidance_sheets_pdfs/section6.pdf
- គោលការណ៍ណែនាំចំនួន ៤ ទំព័រស្តីពីទិសដៅនៃជីវភាពរស់នៅ- ការវិភាគ និង ការកសាងសមត្ថភាព http://www.streaminitiative.org/Library/bpg/index.html
- ជីវភាពរស់នៅ និងវិស័យជលផលនៅក្នុងអាងទន្លេមេគង្គក្រោម : ការយល់ដឹងពីគោលគំនិតនៃទិសដៅនៃជីវភាពរស់នៅ។ ការអភិវឌ្ឍន៍ទន្លេមេគង្គ សេរីលេខ ៥ http://www.streaminitiative.org/Library/pdf/pdf-india/FisheriesLivelihoodsStudy.pdf

**តើគោលនយោបាយទាំងនេះចេញមកពីណា?**

រាល់សេរីនៃគោលនយោបាយសង្ខេប គឺរៀបចំឡើងដោយ "**ការគាំទ្រដល់ការគ្រប់គ្រងប្រភពធនធានវារីជាតក្នុងតំបន់**" **the Support to Regional Aquatic Resources Management (STREAM)** ដែលផ្តួចផ្តើមដោយបណ្តាញមជ្ឈមណ្ឌលវារីវប្បកម្មនៅអាស៊ីប៉ាស៊ីហ្វិច **(NACA)**។

គោលនយោបាយសង្ខេបលេខ ២ តមកពី គោលនយោបាយសង្ខេបលេខ ១ ដែលបរិយាយអំពីការព្រមព្រៀងគ្នាផ្លាស់ប្តូរគោលនយោបាយ និង អ្នកពាក់ព័ន្ធទាំងឡាយ។ អត្ថបទរៀបរាប់ផងដែរពីបទពិសោធន៍ដែលទទួលបានពី **ជំនួយនៃគម្រោងសហប្រតិបត្តិការបច្ចេកទេសរបស់អង្គការ FAO** ដើម្បីកាត់បន្ថយភាពក្រីក្រតាមរយៈបង្កើនការគ្រប់គ្រងធនធានវារីជាតនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិច ដោយចែករំលែកនូវរាល់ការយល់ដឹងពីលទ្ធផលនៃការវិភាគ និង ទិសដៅសម្រាប់បង្កើនជីវភាពរស់នៅ។

ព័ត៌មានបន្ថែមសូមស្រាវជ្រាវតាមគេហទំព័រ www.streaminitiative.org/Library/India/india.html ឬទាក់ទង STREAM, NACA មហាវិថី ស៊ូរ៉ាវ៉ាឌី បរិវេណ នាយកដ្ឋានជលផល សាកលវិទ្យាល័យ កាសេតសាទ សង្កាត់ ឡាយ៉ាវ ខ័ណ្ឌ ចាទូចាក ទីក្រុង បាងកក ១០៩០០ ប្រទេស ថៃឡង់ត៍ ទូរសារលេខ (៦៦២) ៥៦១-១៧២៧, ទូរស័ព្ទលេខ (៦៦២)៥៦១-១៧២៨។